ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២១២.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគដីនៅលើកោះស្តេច នៅជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រគល់ជូនប្រជាពលរដ្ឋជាកម្មសិទ្ធិ និងមួយចំណែក រក្សាទុកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- លិខិតលេខ ៥៣៦/១៧ ល.សចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៧ របស់រដ្ឋបាលខេត្តកោះកុង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១** : ត្រូវបានធ្វើអនុបយោគដីនៅលើកោះស្តេច ទំហំ ៩២ ហិកតា "កៅសិបពីរហិកតា" ទៅជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រគល់ជូនប្រជាពលរដ្ឋជាកម្មសិទ្ធិ និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋស្ថិតនៅ ភូមិកោះស្តេច ឃុំកោះស្តេច ស្រុកគិរីសាគរ ខេត្តកោះកុង ។

**មាត្រា ២** : ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកោះកុង ដើម្បីប្រគល់ជូនប្រជាពលរដ្ឋ និងរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គមនៅក្នុងមូលដ្ឋាន ។

**មាត្រា ៣** : ត្រូវបានអនុញ្ញាតឲ្យបន្តការចេញប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងការធ្វើចរន្តការផ្ទេរសិទ្ធិលើក្បាលដីដែលបានចេញប័ណ្ណកន្លងមក ។

**មាត្រា ៤** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ច័ន្ទ ១ កើត ខែ បុស្ស ឆ្នាំ រកា ព.ស. ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែ ធ្នូ គ.ស. ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

## សម្រេច

**ប្រការ១.**_

ត្រូវបានតែងតាំងប្រធាននិងអនុប្រធាននៃគណៈកម្មការនីមួយៗនិងលេខាធិការដ្ឋានដូចខាងក្រោម ៖

១-គណៈកម្មការសន្តិសុខនិងសណ្តាប់ធ្នាប់

- ឯកឧត្តមសន្តិបណ្ឌិតនាយឧត្តមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ ប្រធាន
- ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អនុប្រធាន
- ឯកឧត្តម **ឃួង ស្រេង** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ អនុប្រធាន

២-គណៈកម្មការកីឡានិងបទប្បញ្ញត្តិ

- ឯកឧត្តម **វ៉ាត់ ចំរើន** អគ្គលេខាធិការគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ប្រធាន
- លោក **ហ៊ិន សាមុត** ប្រធាននាយកដ្ឋានអប់រំកាយនិងកីឡា អនុប្រធាន
- លោក **ថោង ធន** មន្ត្រីគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា អនុប្រធាន

៣-គណៈកម្មការហិរញ្ញវត្ថុនិងផ្គត់ផ្គង់

- ឯកឧត្តម **ប៉ូ រតនា** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធាន
- លោកស្រី **នៃ សុគា** ប្រធាននាយកដ្ឋានអាជ្ញាធរសវនកម្មជាតិ អនុប្រធាន
- លោកស្រី **ស្នូង ស៊ីណារ័ត្ន** មន្ត្រីហិរញ្ញវត្ថុ គ.ជ.អ.ក អនុប្រធាន

៤-គណៈកម្មការហ្គេម IT

- លោក **ប៊ុយ សុគ័ណ្ឋា** អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ គ.ជ.អ.ក ប្រធាន
- លោក **វ៉ាត់ ពន្លឺ** មន្ត្រីគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា អនុប្រធាន

៥-គណៈកម្មការទីលានប្រកួត

- លោក **ជួង មាសចំរើន** ប្រធាននាយកដ្ឋានកីឡាសិស្ស-និស្សិត ប្រធាន
- លោក **ឌិន សុបញ្ញា** អនុប្រធានរដ្ឋបាល គ.ជ.អ.ក អនុប្រធាន
- លោក **ម៉ៃ សំអាត** មន្ត្រីគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា អនុប្រធាន

៦-គណៈកម្មការវេជ្ជសាស្ត្រនិងដូភីង

- លោកវេជ្ជបណ្ឌិត **ស្តើង ជា** ប្រធានគណៈកម្មការវេជ្ជសាស្ត្រ គ.ជ.អ.ក ប្រធាន
- លោក **អ៊ិត ឡេង** ប្រធានការិយាល័យភ្នាក់ងារជាតិប្រឆាំងដូភីង អនុប្រធាន
- លោកស្រីវេជ្ជបណ្ឌិត **ហួត ចាន់ធានី** មន្ត្រីគណៈកម្មការវេជ្ជសាស្ត្រ គ.ជ.ប.ក អនុប្រធាន

៧-គណៈកម្មការអ្នកស្ម័គ្រចិត្ត

| | | | |
|---|---|---|---|
| - លោក | **ណាយ ផាណា** | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ គ.ជ.អ.ក | ប្រធាន |
| - លោក | **ច្បាន រិច** | មន្ត្រីគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | អនុប្រធាន |

៨-គណៈកម្មការវប្បធម៌ បរិស្ថាន និងអប់រំកីឡា

| | | | |
|---|---|---|---|
| - លោក | **គុប បញ្ញា** | ប្រធាននាយកដ្ឋានគម្រោងកម្មវិធី គ.ជ.អ.ក | ប្រធាន |
| - លោក | **ធម្ម អក្ខារ៉ា** | ប្រធានវិទ្យាស្ថានជាតិអប់រំកាយនិងកីឡា | អនុប្រធាន |
| - លោក | **សឿ បញ្ញា** | មន្ត្រីគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | អនុប្រធាន |

៩-គណៈកម្មការស្នាក់នៅនិងហូបចុក

| | | | |
|---|---|---|---|
| - ឯកឧត្តម | **គែម ម៉ឺន** | ប្រធានមជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ | ប្រធាន |
| - លោក | **ប៉ុន សុខ** | ប្រធានមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | អនុប្រធាន |
| - លោក | **ថោង វឌ្ឍស័ក្ក** | មន្ត្រីគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | អនុប្រធាន |

១០-គណៈកម្មការផ្សព្វផ្សាយនិងព័ត៌មាន

| | | | |
|---|---|---|---|
| - ឯកឧត្តម | **ជា ច័ន្ទបរិបូរណ៍** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | ប្រធាន |
| - លោក | **ភាំង សុធា** | អនុប្រធានរដ្ឋបាល គ.ជ.អ.ក | អនុប្រធាន |
| - លោក | **មាស សារ៉េត** | មន្ត្រីគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | អនុប្រធាន |

១១-គណៈកម្មការទីផ្សារនិងចលនទ្រព្យ

| | | | |
|---|---|---|---|
| - កញ្ញា | **តៃ លីដា** | អនុប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈ ទីផ្សារកីឡា គ.ជ.អ.ក | ប្រធាន |
| - លោកស្រី | **អ៊ីឡូដា ប្រាក់សង្គល** | មន្ត្រីគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | អនុប្រធាន |

១២-គណៈកម្មការដឹកជញ្ជូន

| | | | |
|---|---|---|---|
| - លោក | **ឯម ហៀង** | ប្រធាននាយកដ្ឋានរដ្ឋបាល គ.ជ.អ.ក | ប្រធាន |
| - ឯកឧត្តម | **សុខ គុងហាប់** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |

១៣-គណៈកម្មការពិធីការ

| | | | |
|---|---|---|---|
| - លោកជំទាវ | **ម៉ក់ វណ្ណាស៊ីថា** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ប្រធាន |
| - លោកស្រី | **សោ ម៉ាល័យ** | មន្ត្រីគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | អនុប្រធាន |

១៤-គណៈកម្មការពិធីបើកនិងបិទ

| | | | |
|---|---|---|---|
| - ឯកឧត្តម | **ថោង ខុន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ប្រធាន |
| - ឯកឧត្តម | **ព្រឿង ឈាង** | ទីប្រឹក្សាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| - ឯកឧត្តម | **ជាច គេន** | ទីប្រឹក្សាក្រសួងវប្បធម៌និងចិត្រសិល្បៈ | អនុប្រធាន |
| - លោក | **លន់ សាមឌី** | មន្ត្រីគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | អនុប្រធាន |

១៥-លេខាធិការដ្ឋាន

| | | | |
|---|---|---|---|
| - លោក | **ញាន សុខចសាល** | ប្រធាននាយកដ្ឋានទំនាក់ទំនងការបរទេស និងកិច្ចសហប្រតិបត្តិការ គ.ជ.អ.ក | ប្រធាន |
| - ឯកឧត្តម | **គុយ សាវុធ** | អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| - ឯកឧត្តម | **សេរី ជំនះ** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| - លោក | **អ៊ូ សុផាន់នី** | មន្ត្រីគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | អនុប្រធាន |

**ប្រការ២ ._**

ការបំពេញបន្ថែមអនុប្រធាននិងការរៀបចំសមាជិកនៃគណៈកម្មការនីមួយៗ និងលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ជ.ម.អ.** ។

**ប្រការ៣ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១ កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ